**កំណត់ត្រាសង្ខេបរបស់ ម.ស.ម.ក**

ខែកុម្ភៈ ឆ្នាំ២០១៣

# កំណែទម្រង់ប្រព័ន្ធតុលាការ

## ខ្លឹមសារសង្ខេប

កំណត់ត្រាសង្ខេបនេះគូសបញ្ជាក់ពីបច្ចុប្បន្នភាពនៃប្រព័ន្ធតុលាការក្នុងព្រះរាជាណាចក្រកម្ពុជា("កម្ពុជា") វិភាគលើចំណុចខ្វះខាតមួយចំនួនក្នុងការបំពេញមុខងាររបស់ប្រព័ន្ធយុត្តិធម៌ និងតុលាការ ហើយនិងផ្តល់នូវអនុសាសន៍មួយចំនួនដើម្បីធ្វើកំណែទម្រង់ ដែលនឹងផ្តល់នូវអត្ថប្រយោជន៍ដ៏ធំធេងដល់ការបំពេញតួនាទីរបស់ប្រព័ន្ធយុត្តិធម៌ និងជួយសម្រួលឲ្យឯករាជ្យភាពនៃប្រព័ន្ធតុលាការក្នុងប្រទេសកម្ពុជាបានកាន់តែប្រសើរឡើង។ ផ្នែកដំបូងនៃកំណត់ត្រាសង្ខេបនេះផ្តល់នូវសាវតារអំពីដំណើរការដែលប្រព័ន្ធយុត្តិធម៌ និងតុលាការប្រតិបត្តិនាពេលបច្ចុប្បន្ន រួមទាំងការវិភាគលើបច្ចុប្បន្នភាពនៃនីតិរដ្ឋ ការបែងចែកអំណាច និងឯករាជ្យភាពរបស់តុលាការក្នុងប្រទេសកម្ពុជា។ ផ្នែកទីពីរនៃកំណត់ត្រា វិភាគជាលម្អិតបន្ថែមទៀតពីឧបសគ្គមួយចំនួនដែលរាំងស្ទះដល់ការបំពេញមុខងារឲ្យបានត្រឹមត្រូវ ប្រព័ន្ធតុលាការឯករាជ្យ ពោលគឺ ការខកខានពុំបានអនុម័តនូវច្បាប់សំខាន់ៗ កង្វះឯករាជ្យភាពរបស់ប្រព័ន្ធតុលាការ ព្រមទាំងការខកខានពុំបានផ្តល់ធនធាន និងការបណ្តុះបណ្តាលឲ្យបានគ្រប់គ្រាន់លើវិស័យច្បាប់ និងយុត្តិធម៌នានា។ ផ្នែកបញ្ចប់នៃកំណត់ត្រាសង្ខេបដាក់ចេញនូវអនុសាសន៍ជាក់លាក់ និងប្រាកដប្រជាសម្រាប់កំណែទម្រង់ប្រព័ន្ធតុលាការ ហើយកំណែទម្រង់ទាំងនេះ ត្រូវបានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ជឿថាមានសារៈសំខាន់ជាស្នូលដើម្បីធ្វើឲ្យការបំពេញមុខងារបានត្រឹមត្រូវ និងធ្វើឲ្យតុលាការមានឯករាជ្យ ដែលអាចមានសមត្ថភាពបម្រើផលប្រយោជន៍ជូនប្រជាពលរដ្ឋកម្ពុជា និងជាការប្រតិបត្តិតាមមាគ៌ានីតិរដ្ឋ។

កំណត់ត្រាសង្ខេបនេះកំណត់បង្ហាញពីចំណុចសំខាន់ៗចំនួនបួន នៃកំណែទម្រង់ប្រព័ន្ធតុលាការដើម្បីពង្រឹងឯករាជ្យភាព និងសុចរិតភាពរបស់ស្ថាប័នតុលាការៈ

១. សេចក្តីព្រាងច្បាប់គួរតែត្រូវធ្វើ និងអនុម័តឲ្យបានឆាប់ ហើយវិសោធនកម្មចាំបាច់ត្រូវតែធ្វើឡើងលើច្បាប់កំពុងតែនៅជាធរមាន ដើម្បីធានាថា ច្បាប់ទាំងនេះអាចអនុវត្តបានយ៉ាងត្រឹមត្រូវ និងមានអានុភាពពិតប្រាកដលើដំណើរការនៃប្រព័ន្ធច្បាប់ និងតុលាការកំពុងប្រតិបត្តិ។

២. ការអប់រំដល់សហគមន៍គួរតែបានផ្តល់ជូន និងព័ត៌មានត្រូវបានផ្សព្វផ្សាយដើម្បីធានាថា ប្រជាពលរដ្ឋមានការយល់ដឹងពីសិទ្ធិតាមផ្លូវច្បាប់របស់ពួកគេ។

៣. ការពង្រឹងសមត្ថភាពគួរតែធ្វើឡើងតាមរយៈការបណ្តុះបណ្តាល និងធនធានផ្នែកច្បាប់នានា ដើម្បីផ្តល់

ឲ្យមេធាវីមានជំនាញ និងចំណេះដឹង ដែលជាអ្នកឯកទេសវិជ្ជាជីវៈនៅក្នុងជំនាញរបស់ពួកគេ និងដើម្បីធ្វើឲ្យបុគ្គលិកនានារបស់ស្ថាប័នតុលាការមានសមត្ថភាពពេញលេញ។ ចៅក្រម និងមេធាវី ត្រូវតែមានចំណេះដឹងជ្រៅជ្រះក្នុងបញ្ហាសិទ្ធិ និងនីតិវិធីតាមផ្លូវច្បាប់នានា ប៉ុន្តែក៏ត្រូវមានសម្ភារៈ និងកញ្ចប់ថវិកាគ្រប់គ្រាន់ ដើម្បីលើកស្ទួយ និងអនុវត្តច្បាប់។

៤. ការប្ដេជ្ញាជាបន្ទាន់ និងគ្មានលក្ខខណ្ឌ គួរតែធ្វើឡើងពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ("រ.រ.ក") និងស្ថាប័នតុលាការ ដែលធានាថា តុលាការនឹងមិនត្រូវបានគេប្រើប្រាស់ជាឧបករណ៍នយោបាយ ដើម្បីបំបិទសំឡេងអ្នកប្រឆាំង និងដើម្បីរារាំងដល់ការពិភាក្សានានានោះឡើយ។

អនុសាសន៍ទាំងនេះ មានសារៈសំខាន់ណាស់ចំពោះកំណែទម្រង់ប្រព័ន្ធតុលាការដែលពោរពេញដោយអត្ថន័យ ស្របតាមគោលបំណងនៃការសម្រេចបាននូវប្រព័ន្ធតុលាការមួយឯករាជ្យដែលប្រតិបត្តិនៅក្នុងក្របខណ្ឌនៃនីតិរដ្ឋ។ កំណត់ត្រាសង្ខេបនេះ គាក់តែងឡើយដោយ ម.ស.ម.ក ជាអង្គការមិនមែនរដ្ឋាភិបាល មិនចូលបក្សសម្ព័ន្ធ ឯករាជ្យ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យនិងគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅទូទាំងប្រទេសកម្ពុជា។

## សាវតារៈ ស្ថានភាពនៃស្ថាប័នតុលាការៈ ការបែងចែកអំណាច នីតិរដ្ឋ និងឯករាជ្យភាពនៃស្ថាប័នតុលាការ

នៅកម្ពុជា ពុំទាន់មានការបែងចែកអំណាចពិតប្រាដកនោះទេ។ ឥទ្ធិពលរបស់អង្គនីតិប្រតិបត្តិកំពុងតែបន្តរាលដាលនៅក្នុងស្ថាប័នតុលាការ និងតុលាការនៅខ្វះឯករាជ្យភាពនៅឡើយ។ ស្របពេលដែល រ.រ.ក បានថ្លែងពីការប្ដេជ្ញាចិត្តរបស់ខ្លួនដើម្បីឲ្យមានកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ តែជាក់ស្ដែងមានការរីកចម្រើនតិចតួចបានត្រូវធ្វើឡើង និងវិវឌ្ឍន៍លើផ្នែកច្បាប់ និងប្រព័ន្ធតុលាការបានធ្លាក់ចុះគួរឲ្យកត់សម្គាល់ស្ថិតនៅពីក្រោយការ រីកចម្រើនដែលគេបានសង្កេតឃើញនៅតាមផ្នែកផ្សេងៗទៀត។ មានគម្លាតពីគ្នាកាន់តែខ្លាំងទៅៗរវាងការធានាស្របតាមរដ្ឋធម្មនុញ្ញទាក់ទិននឹងឋានៈនៃស្ថាប័នតុលាការ និងវិធីសាស្ត្រដែលស្ថាប័នតុលាការអនុវត្តមុខងាររបស់ខ្លួនជាក់ស្ដែង។ នៅគ្រាដែល គម្លាតនេះកាន់តែធំទៅៗ ទំហំសម្រាប់ការរិះគន់ និងកិច្ចពិភាក្សាកំពុងតែរួមតូចទៅៗ ដោយសារតែតុលាការត្រូវបានគេប្រើជាឧបករណ៍នយោបាយដើម្បីបំបិទសំឡេងប្រឆាំង និងអ្នកមាននិន្នាការជំទាស់។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") បញ្ញត្តពីឯករាជ្យភាពរបស់ ប្រព័ន្ធតុលាការ និងកំណត់ពីមុខងាររបស់តុលាការ ដើម្បី *"ធានា និងប្រកាន់ភ្ជាប់នូវភាពមិនលម្អៀង ព្រមទាំងការពារសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ"*។[1] យ៉ាងណាក្ដី នៅក្នុងបរិយាកាសនយោបាយបច្ចុប្បន្ននេះ ស្ថាប័នតុលាការពុំមានលទ្ធភាពអាចបំពេញតាមការធានានេះនៅឡើយទេ ហើយឥទ្ធិពលពីខាងក្រៅជ្រៀតជ្រែកចូលក្នុងតុលាការជាប្រចាំ។ រឿងក្ដីមាន

---

[1]មាត្រា១២៨ នៃរដ្ឋធម្មនុញ្ញ

ចរិតលក្ខណៈនយោបាយមួយចំនួនត្រូវបានធ្វើឡើងប្រឆាំងនឹងអ្នកនយោបាយជំទាស់ អ្នកទាមទារសិទ្ធិដីធ្លី និងបុគ្គលដែលហ៊ាននិយាយក្នុងកិច្ចការពារផ្នែកសិទ្ធិមនុស្ស។ ផ្ទុយទៅវិញ អ្នកដែលមានទំនាក់ទំនងជាមួយរដ្ឋាភិបាល ឬតួនាទីក្នុងជួរអាជ្ញាធរទទួលបាននូវនិទណ្ឌភាព បើទោះជាពួកគេត្រូវបានចោទប្រកាន់ពីការប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរក៏ដោយ។ ការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌដែលដឹកនាំដោយតុលាការក្នុងប្រទេសកម្ពុជា ត្រូវបានធ្វើឡើងតាមការជ្រើសរើស និងមិនស៊ីសង្វាក់គ្នា ដែលជាការបង្កើតឲ្យមានបរិយាកាសមួយពុំមាននីតិរដ្ឋ។ នៅក្នុងបរិយាកាសបែបនេះ ពុំអាចឲ្យប្រជាពលរដ្ឋខ្មែរមានភាពជឿជាក់ ឬក៏ទំនុកចិត្តលើប្រព័ន្ធតុលាការរបស់ខ្លួននោះឡើយ ហើយមានការទទួលស្គាល់ដោយក្តីមន្ទិលសង្ស័យ និងភាពភ័យខ្លាចជំនួសការយល់ថាតុលាការគឺជាស្ថាប័នមួយដែលជម្លោះ និងការចោទប្រកាន់នានា អាចត្រូវបានដោះស្រាយដោយសន្តិវិធី និងយុត្តិធម៌។ ថ្វីបើជាការពិតដែលថាប្រជាពលរដ្ឋនៅតែពុំទាន់មានភាពជឿជាក់ចំពោះប្រព័ន្ធតុលាការ ក៏ពុំទាន់មានចលនាប្រមូលផ្តុំនូវការគាំទ្រជាសាធារណៈសម្រាប់កំណែទម្រង់តុលាការ។ ខណៈភាពអសកម្មនេះប្រហែលជាយ៉ាងហោចណាស់ក៏ដោយសារតែផ្នែកមួយដែលថា រ.រ.ក និងអាជ្ញាធរបានបង្ហាញពីឆន្ទៈដើម្បីគាបសង្កត់ក្រុមប្រឆាំងដោយប្រើហិង្សា និងប្រើកម្លាំងដែលអាចបណ្តាលឲ្យមានគ្រោះថ្នាក់ដល់អាយុជីវិតនៅក្នុងស្ថានភាពមួយចំនួន ក៏អាចមានការរួមចំណែកផងដែរនៅក្នុងការពន្យារពេលនៃការធ្វើកំណែទម្រង់របស់ រ.រ.ក ដែលខ្លួនបានទទួលរ៉ាប់រងធ្វើអស់រយៈពេលជាយូរមកហើយ។

នៅក្នុងកម្រិតដែលរឹតតែជាក់លាក់ ដំណើរការដែលសវនាការត្រូវបានធ្វើឡើងគឺបង្ហាញពីកង្វះខាតនៃធនធាននានា គុណភាពនៃការបណ្តុះបណ្តាលនៅពុំទាន់បានគ្រប់គ្រាន់ និងខ្វះការយល់ដឹងពីបទដ្ឋានសិទ្ធិមនុស្សពាក់ព័ន្ធនានា។ ជានិច្ចកាល នីតិវិធីជាមូលដ្ឋានមិនទាន់ត្រូវបានអនុវត្តតាមឲ្យបានត្រឹមត្រូវនោះទេ ហើយការជំនុំជម្រះក្តីអាចត្រូវបានធ្វើឡើងដោយមានលក្ខណៈប្រញាប់ប្រញាល់។ ការឃុំខ្លួនបណ្តោះអាសន្នគឺកើតមានជាទូទៅចំពោះនីតិជន និងអនីតិជន ហើយពុំមានច្បាប់ស្តីពីអនីតិជនដោយឡែកនោះទេ។ ជាទូទៅ ប្រជាពលរដ្ឋមានការយល់ដឹងតិចតួចចំពោះសិទ្ធិតាមផ្លូវច្បាប់របស់ខ្លួន និងរបៀបរបបក្នុងការអនុវត្តន៍សិទ្ធិទាំងនោះ ហើយប្រព័ន្ធច្បាប់មានបន្ទុកធ្ងន់ជាមួយនឹងចំនួនករណីច្រើនពេក។

ចាប់តាំងពី ម.ស.ម.ក បានចាប់ផ្តើមនូវគម្រោងសង្កេតការណ៍សវនាការរបស់ខ្លួន (“គ.ស.ស”) ក្នុងឆ្នាំ ២០០៩មក មានភាពរីកចម្រើនជាលំដាប់ក្នុងការប្រកាន់ខ្ជាប់នូវបទដ្ឋានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ទោះជាយ៉ាងនេះក្តី ក្តីព្រួយបារម្ភចម្បងៗមួយចំនួននៅតែមាននិងប្រាកដណាស់ថាកំណែទម្រង់ដ៏សំខាន់គឺចាំបាច់ត្រូវតែមាន ប្រសិនបើការរីកចម្រើនពិតប្រាកដណាមួយនឹងត្រូវធ្វើឡើង។ ក្របខណ្ឌតុលាការដែលអាចជឿជាក់ និងមានស្ថេរភាពគឺសំខាន់ណាស់ ប្រសិនបើនីតិរដ្ឋត្រូវបានគេគោរពតាមនោះ ដែលអាចសម្រេចបានដោយមានការផ្លាស់ប្តូរជាមូលដ្ឋាន និងការគោរពដ៏ជាក់លាក់ដល់ស្មារតីរដ្ឋធម្មនុញ្ញ។

## ឧបសគ្គចំពោះស្ថាប័នតុលាការក្នុងការបំពេញមុខងារឲ្យបានត្រឹមត្រូវក្នុងប្រទេសកម្ពុជា

## ការខកខានពុំបានអនុម័តច្បាប់សំខាន់ៗ

ឧបសគ្គចម្បងមួយក្នុងចំណោមឧបសគ្គនានាដែលរាំងស្ទះដល់ការធ្វើកំណែទម្រង់ប្រព័ន្ធតុលាការក្នុងប្រទេសកម្ពុជានោះគឺការបរាជ័យរបស់ រ.រ.ក ក្នុងការអនុម័តច្បាប់សំខាន់ៗ ដែលនឹងកំណត់ពីតួនាទី និងលក្ខន្តិកៈជាផ្លូវការរបស់សមាជិកនៃស្ថាប័នតុលាការ។ បើពុំមានច្បាប់ទាំងនេះទេនោះ ព្រំដែនអនុវត្តរវាងស្ថាប័ននីតិបញ្ញត្តិ នីតិប្រតិបត្តិ និងស្ថាប័នតុលាការ នៅតែមានភាពពុំដាច់ស្រឡះ ហើយឯករាជ្យភាពរបស់ស្ថាប័នតុលាការបានប៉ះពាល់ដ៏ធ្ងន់ធ្ងរ។ តាមយុទ្ធសាស្ត្រកំណែទម្រង់ផ្នែកច្បាប់ និងតុលាការរបស់ខ្លួន ("យុទ្ធសាស្ត្រ") រ.រ.ក កំណត់ពីគោលបំណងរបស់ខ្លួនដើម្បី *"បង្កើតនូវក្របខណ្ឌច្បាប់ និងប្រព័ន្ធតុលាការដែលមានស្ថេរភាពមួយ ដែលប្រជាពលរដ្ឋសាមញ្ញ ក៏ដូចជា អ្នកវិនិយោគជាតិ និងអន្តរជាតិ អាចប្រកបមុខជំនួញរបស់ពួកគេដោយមានទំនុកចិត្តថាសិទ្ធិរបស់ពួកគេត្រូវបានការពារគ្រប់ពេល តាមរយៈប្រព័ន្ធយុត្តិធម៌ដែលមានតម្លាភាព អាចពឹងទុកបាន និងយុត្តិធម៌ ដែលប្រកបដោយការជឿជាក់ និងស្ថេរភាព"*[2] យុទ្ធសាស្ត្រនេះត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រី ("គ.រ.ម") កាលពីខែមិថុនា ឆ្នាំ២០០៣ ប៉ុន្តែមានផលប៉ះពាល់មានកម្រិតរហូតមកទល់បច្ចុប្បន្ននេះ។ ការខកខានដើម្បីធ្វើឲ្យមានឥទ្ធិពលជាក់លាក់គឺដោយសារតែបញ្ហាចម្បងដែលថាច្បាប់សំខាន់ៗមួយចំនួនដែល រ.រ.ក បានស្នើឡើងគឺនៅពុំទាន់បានអនុម័តនៅឡើយទេ។

ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់តុលាការស្ថិតនៅដំណាក់កាលព្រាងនៅឡើយ ហើយបច្ចុប្បន្នកំពុងតែស្ថិតនៅក្រោមការត្រួតពិនិត្យដោយក្រសួងយុត្តិធម៌។ ច្បាប់នេះនឹងបង្កើតបានជាក្រមមួយសម្រាប់ជាមាគ៌ាដល់ស្ថាប័នតុលាការប្រតិបត្តិតាម ដែលផ្តល់នូវភាពស៊ីសង្វាក់ និងតម្លាភាពដែលប្រព័ន្ធតុលាការកំពុងតែខ្វះចន្លោះនាពេលបច្ចុប្បន្ននេះ ហើយដែលជួយកសាងនូវក្របខណ្ឌគតិយុត្តដែលការអភិវឌ្ឍន៍ និងកំណែទម្រង់អាចមាននិរន្តភាព។

ស្រដៀងគ្នានេះដែរ ច្បាប់ស្តីពីលក្ខន្តិកៈរបស់ចៅក្រម និងព្រះរាជអាជ្ញាគឺកំពុងស្ថិតនៅក្នុងសេចក្តីព្រាងនៅឡើយ ហើយបច្ចុប្បន្ននេះ កំពុងតែនៅក្នុងការត្រួតពិនិត្យរបស់ គ.រ.ម។ ល្គឹកណាច្បាប់នេះត្រូវបានអនុម័ត ចៅក្រមនឹងនៅតែបន្តត្រូវបានគ្រប់គ្រងដោយវិធាននៃមន្ត្រីរាជការទូទៅ ដូច្នេះច្បាប់នេះគឺចាំបាច់ជួយពង្រឹងនូវគោលការណ៍រដ្ឋធម្មនុញ្ញនៃឯករាជ្យភាពរបស់តុលាការ។ បច្ចុប្បន្ននេះ ចៅក្រមពុំមានការធានាអំពីអាណត្តិនៃមុខតំណែងរបស់ខ្លួននោះទេ ហើយស្ថាប័ននីតិប្រតិបត្តិអាចឲ្យចៅក្រមមានអាយុលើស៦០ឆ្នាំចូលនិវត្តន៍ ប៉ុន្តែនៅតែអាចឲ្យបន្តតំណែងបានចំពោះចៅក្រមដែលមានអាយុលើសពីនេះតាមឆន្ទានុសិទ្ធិ។ ដោយហេតុនេះ ចៅក្រមទាំងឡាយណាដែលធ្វើការវិនិច្ឆ័យស្របតាមគោលនយោបាយរបស់រដ្ឋាភិបាលអាចមានសង្ឃឹមទទួលបានវិជ្ជាជីវៈជាចៅក្រមបានយូរជាងចៅក្រមណាដែលដើរផ្ទុយទៅផ្សេង។ បើពុំមានច្បាប់កំណត់ពីលក្ខណៈសម្បត្តិសម្រាប់ការតែងតាំង និង

[2] រ.រ.ក យុទ្ធសាស្ត្រកំណែទម្រង់ប្រព័ន្ធច្បាប់ និងតុលាការ អនុម័តដោយគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៣ អាចស្វែងរកបានតាមរយៈគេហទំព័រ៖http://www.cljr.gov.kh/eng/library/doc/06_Legal.and.Judicial.Reform.Strategy.pdf

ទទួលអាណត្តិរបស់ចៅក្រម និងព្រះរាជអាជ្ញាទេនោះ មានឥទ្ធិពលលើចៅក្រមដែលមាននិន្នាការប្រឆាំង ធ្វើឲ្យអាណត្តិនៃមុខតំណែងរបស់ពួកគេត្រូវបានការកាត់បន្ថយ។

ការធ្វើវិសោធនកម្មច្បាប់ស្តីពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ("ច.ឧ.អ.ច") ត្រូវបានធ្វើឡើងកាលពីខែមេសា ឆ្នាំ២០០២ ហើយបានអនុម័តដោយ គ.រ.ម ប៉ុន្តែនៅរង់ចាំការអនុម័តយល់ព្រមពីរដ្ឋសភា។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ("ឧ.ក.អ.ច") មានបំណងធ្វើជាស្ថាប័នឯករាជ្យមួយ ដោយទទួលខុសត្រូវចំពោះការដាក់ពិន័យលើចៅក្រម ហើយស្ថាប័ននេះមានអំណាចតែងតាំង បណ្តេញចេញពីមុខដំណែង ដំឡើងឋានន្តរសក្តិ និងដាក់ពិន័យលើចៅក្រម។ ឯករាជ្យភាពរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមបច្ចុប្បន្ននេះត្រូវបានធ្វើឲ្យធ្លាក់នូវកិត្យានុភាព ដោយហេតុថា ស្ថិតនៅក្រោម ច.ឧ.អ.ច តាមរូបមន្តថ្មីរបស់ខ្លួន សមាជិកម្នាក់របស់ ឧ.ក.អ.ច គឺជារដ្ឋមន្ត្រីរបស់រដ្ឋាភិបាលមកពីក្រសួងយុត្តិធម៌។ ខណៈវិសោធនកម្មដែលបានស្នើឡើងអនុវត្តតាមនីតិវិធីមួយចំនួនសំដៅធ្វើការកែប្រែដោយហេតុថា សមាសភាពរបស់ ឧ.ក.អ.ច ធ្វើឲ្យអន្តរាយដល់ឯករាជ្យភាពនៃប្រព័ន្ធតុលាការ (ឧទាហរណ៍ៈ តាមរយៈការស្នើឡើងថា កញ្ចប់ថវិកាឯករាជ្យមួយត្រូវតែកំណត់ប្រសើរជាងការលៃទុកដោយក្រសួងយុត្តិធម៌ ដែលនេះជាបញ្ហានៅពេលបច្ចុប្បន្ន) វិសោធនកម្មនេះ គឺខ្វះខាតចំណុចខ្លឹម ហើយពុំបានដោះស្រាយនូវបញ្ហាសំខាន់ៗដូចជាសមាជិកមួយរូបរបស់ស្ថាប័ននីតិប្រតិបត្តិក៏ជាសមាជិករបស់ ឧ.ក.អ.ច ដែរ។

គួរឲ្យស្រងាកចិត្ត នៅគ្រាដែលការធ្វើវិសោធនកម្មដែលមានភាពចាំបាច់បំផុតបានអូសបន្លាយពេល លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ថ្មីនេះៗបានចុះហត្ថលេខាលើអនុក្រឹត្យស្តីពីការបង្កើតអង្គភាពថ្មីមួយដើម្បីស៊ើបអង្កេតលើការប្រព្រឹត្តកំហុសឆ្គងរបស់ចៅក្រម។ "អង្គភាពអធិការកិច្ច" នឹងបង្កើតបានជាផ្នែកនៃក្រុមប្រឹក្សាវិន័យរបស់ ឧ.ក.អ.ច ហើយគណៈកម្មាធិការរបស់អង្គភាពនេះនឹងរួមបញ្ចូលសមាជិករបស់ស្ថាប័ននីតិប្រតិបត្តិ ដែលជាការបោះជំហានថយក្រោយនៅក្នុងន័យយុទ្ធសាស្ត្រ និងជាការប៉ះទង្គិចមួយបន្ថែមទៀតដល់ឯករាជ្យភាពរបស់តុលាការ។

ទោះបីជាច្បាប់ស្តីពីយុត្តិធម៌អនីតិជនត្រូវបានគ្រោងឡើង ច្បាប់ដោយឡែកសម្រាប់ជនជាប់ចោទជាអនីតិជននៅមិនទាន់ត្រូវបានអនុម័តនៅឡើយទេ ហើយបច្ចុប្បន្ននេះអនីតិជនគឺអនុវត្តច្បាប់ដូចគ្នានឹងនីតិជនដែរ។ វ័យនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌក្នុងប្រទេសកម្ពុជាគឺអាយុ១៨ឆ្នាំ[3] តាមធម្មតាអនីតិជនដែលប្រព្រឹត្តបទល្មើសគួរតែស្ថិតនៅក្រោម *"វិធានការត្រួតពិនិត្យ វិធានការអប់រំ វិធានការការពារ និងវិធានការផ្តល់ជំនួយ"* ហើយត្រូវទទួលទោស (ប្រសិនបើមានអាយុ១៤ឆ្នាំ ឬលើសពីនេះ) ប្រសិនបើសកម្មភាពធម្មតា គឺ *"ត្រូវបានជានាតាមរយៈកាលៈទេសៈនៃបទល្មើស ឬក៏បុគ្គលិកលក្ខណៈរបស់អនីតិជននោះ"*[4] ថ្វីបើមានបទប្បញ្ញត្តិនេះក្តី អនីតិជនជារឿយៗត្រូវបានចោទប្រកាន់តាមច្បាប់ដូចគ្នានឹងនីតិជន ដែលទទួលរងទោសកំណត់សម្រាប់នីតិជន និងស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្នហួសកំណត់ និងពុំមានការធានា។ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន គឺត្រូវការជាបន្ទាន់ដើម្បីធានាថា

---

[3] មាត្រា៣៨ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[4] មានប្រភពដូចខាងលើ មាត្រា៣៩

សិទ្ធិរបស់អនីតិជននៅក្នុងប្រព័ន្ធតុលាការគឺត្រូវបានការពារយ៉ាងត្រឹមត្រូវ។

**<u>កង្វះឯករាជ្យភាពរបស់ចៅក្រម</u>**

ស្ថាប័នតុលាការស្ថិតនៅក្រោមឥទ្ធិពលនៃប្រភពមកពីខាងក្រៅតាមវិធីជាច្រើន។ ចៅក្រម និងព្រះរាជអាជ្ញា បច្ចុប្បន្ននេះតែងតាំងដោយក្រសួងយុត្តិធម៌ ឥទ្ធិពលនយោបាយលុកលុយចូលទៅក្នុងតុលាការ ហើយអំពើពុករលួយកើតមានជាប្រចាំ។ ឥទ្ធិពលរបស់រដ្ឋាភិបាលទៅលើតុលាការ អាចត្រូវបានគេមើលឃើញនៅក្នុងចំណោមករណីមួយចំនួន ដែលមានចរិតលក្ខណៈនយោបាយនាប៉ុន្មានឆ្នាំចុងក្រោយ ដូចដែលបង្ហាញនៅខាងក្រោម។

សមាជិកបីរូបរបស់គណៈបក្សសម រង្ស៊ី ដែលជាគណៈបក្សប្រឆាំងដ៏សំខាន់ (ដែលឥឡូវនេះបានបញ្ចូលគ្នាជាមួយគណៈបក្សសិទ្ធិមនុស្សដើម្បីបង្កើតជាគណបក្សសង្គ្រោះជាតិកម្ពុជា) ត្រូវបានដកហូតអភ័យឯកសិទ្ធិសភា ដើម្បីប្រឈមនឹងការចោទប្រកាន់៖ លោក សម រង្ស៊ី លោកស្រី មូរ សុខហួរ និងលោក ហូ វណ្ណ ពួកគាត់ត្រូវបានចោទប្រកាន់ពីបទផ្តល់ព័ត៌មានមិនពិតដែលជាបទល្មើសព្រហ្មទណ្ឌ ឬពីបទបរិហារកេរ្តិ៍ ហើយចំណែក លោក សម រង្ស៊ី និងលោកស្រី មូរ សុខហួរ ត្រូវបានផ្តន្ទាទោស (ការចោទប្រកាន់លើរូបលោក ហូ វណ្ណ ទីបំផុតត្រូវបានទម្លាក់ចោលវិញ)។ ខណៈដែលលោកស្រី មូរ សុខហួរ បច្ចុប្បន្ននេះត្រូវបានសភាប្រគល់អភ័យឯកសិទ្ធិឲ្យវិញ លោក សម រង្ស៊ី នៅតែស្ថិតនៅក្នុងនិរទេសខ្លួន ដែលប្រឈមនឹងទោសជាប់ពន្ធនាគាររយៈពេល១០ឆ្នាំ ប្រសិនបើលោកត្រឡប់មកកាន់កម្ពុជាវិញ សម្រាប់ការចោទប្រកាន់ពីបទពាក់ព័ន្ធនឹងការបំផ្លិចបំផ្លាញ ការញុះញង់ ការផ្តល់ព័ត៌មានមិនពិត និងបទក្លែងបន្លំផែនទី ដែលសុទ្ធតែជាបទល្មើសព្រហ្មទណ្ឌ។

មិនមែនត្រឹមតែអ្នកនយោបាយប៉ុណ្ណោះទេដែលបានទទួលរងនូវការចោទប្រកាន់បែបនេះ៖ លោក ម៉ម សូណង់ដូ ម្ចាស់ស្ថានីយវិទ្យុឯករាជ្យ និងជាអ្នកការពារសិទ្ធិមនុស្សដែលហ៊ាននិយាយមិនសំចៃមាត់ ក៏ត្រូវបានចាប់ខ្លួនកាលពីខែកក្កដា ឆ្នាំ២០១២ ដែលជាប់ពាក់ព័ន្ធទៅនឹងជម្លោះដីធ្លីក្នុងខេត្តក្រចេះ។ កម្លាំងប្រដាប់អាវុធបានចូលទៅក្នុងភូមិប្រម៉ា ដើម្បីបណ្តេញអ្នកភូមិប្រហែល១,000គ្រួសារចេញពីលំនៅដ្ឋាន ហើយនៅពេលដែលអ្នកភូមិបដិសេធមិនព្រមចាកចេញពីលំនៅដ្ឋានរបស់ពួកគេ អាជ្ញាធរបានបើកការបាញ់ប្រហារ ដែលបានសម្លាប់ក្មេងស្រីអាយុ១៤ឆ្នាំម្នាក់ឈ្មោះ ហេង ចន្ថា។ ពុំមានជនណាមួយបានទទួលខុសត្រូវចំពោះការស្លាប់លើរូបកុមារីនោះទេ ហើយការស៊ើបអង្កេតឲ្យបានត្រឹមត្រូវចំពោះឧបទ្ទវហេតុនោះក៏មិនត្រូវបានគេធ្វើឡើងនោះដែរ។ យ៉ាងណាក៏ដោយ បន្ទាប់ពីរឿងរ៉ាវនេះ នគរបាលបានធ្វើការចាប់ខ្លួនមនុស្សជាច្រើននាក់ ដោយធ្វើការចោទប្រកាន់អ្នកភូមិថាបានចូលរួមក្នុងចលនាអបគមន៍ ហើយបានធ្វើការអះអាងថាពួកអ្នកភូមិទាំងនោះកំពុងតែព្យាយាមស្វែងរកឯករាជ្យភាពពីប្រទេសកម្ពុជា។ ថ្វីបើពុំមានភស្តុតាងច្បាស់លាស់ក្នុងការជាប់ពាក់ព័ន្ធនឹងលោក ម៉ម សូណង់ដូ យ៉ាងណាក្តី លោកត្រូវបានចាប់ខ្លួនតាមការចោទប្រកាន់ជាច្រើនករណី រួមមាន បទញុះញង់ឲ្យប្រព្រឹត្តបទល្មើស និងការចូលរួមក្នុងចលនាបះបោរ។ សវនាការកាត់ទោស លោក ម៉ម សូណង់ដូ ធ្វើឡើងក្នុងរាជធានីភ្នំពេញកាលពីខែកញ្ញា ឆ្នាំ២០១២ ហើយលោកត្រូវ

បានផ្តន្ទាទោសឲ្យជាប់ពន្ធនាគាររយៈពេល២០ឆ្នាំកាលពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០១២។ ហេតុដែលលោក ម៉ម សូណង់ដូ ត្រូវបានចាប់ខ្លួន និងករណីរបស់លោកបានបន្តនីតិវិធីរហូតមានការជំនុំជម្រះដោយពុំមាន ភស្តុតាងដាក់បន្ទុក បង្ហាញពីវិសាលភាពនៃឥទ្ធិពលដែល រ.ស.ក ក្តោបក្តាប់លើស្ថាប័នតុលាការ ហើយ ភាពផ្ទុយគ្នាយ៉ាងច្បាស់នោះគឺពុំមានការស៊ើបអង្កេតណាមួយចំពោះករណីស្លាប់លើក្មេងស្រីអាយុ១៤ឆ្នាំដោយសារតែថ្វីដៃរបស់អាជ្ញាធរឡើយ ដែលករណីទាំងពីរនេះបង្ហាញថាច្បាប់មិនត្រូវបានអនុវត្តឲ្យស្មើភាពគ្នា ឬស៊ីសង្វាក់គ្នានោះទេ ព្រមទាំងបង្ហាញពីបញ្ហានិទណ្ឌភាព។ ការផ្តន្ទាទោសលើលោក ម៉ម សូណង់ដូ និងទោសជាប់ពន្ធនាគារ២០ឆ្នាំ បង្ហាញឲ្យឃើញពីគម្លាតដែល រ.ស.ក កំពុងតែមានចេតនាជ្រៀតជ្រែកចូលក្នុងការប្រើប្រាស់យ៉ាងប៉ិនប្រសប់នូវប្រព័ន្ធតុលាការដែលងាយបត់បែន ដើម្បីសម្រេចនូវនយោបាយរបស់ខ្លួន។

ការរួមផ្សំគ្នានៃការផ្តន្ទាទោសដែលមានលក្ខណៈនយោបាយ និងនិទណ្ឌភាពចំពោះអ្នកដែលមានទំនាក់ទំនងស្និតជាមួយអ្នកមានអំណាច មិនត្រឹមតែធ្វើឲ្យប៉ះពាល់ដល់ឯករាជ្យភាពរបស់តុលាការប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដាក់ការគំរាមកំហែងដ៏ធ្ងន់ធ្ងរចំពោះសារៈសំខាន់នៃលទ្ធិប្រជាធិបតេយ្យសេរីនិយម។ ស្ថានភាពនេះគឺជាលទ្ធផលនៃអំពើពុករលួយដែលនៅតែកើតមាន និងការខកខានពុំបានគោរពការប្តេជ្ញាចិត្តដែលបានកំណត់ក្នុងយុទ្ធសាស្រ្ត ហើយដរាបណាអំណាចបង្កើតនិយ័តកម្ម និងដាក់ពិន័យលើស្ថាប័នតុលាការនៅតែស្ថិតក្នុងដៃរបស់ស្ថាប័ននីតិប្រតិបត្តិដដែលនោះ ភាពរីកចម្រើននឹងមិនទទួលបាននោះឡើយ។

សូម្បីតែច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយ ("ច.ប្រ.ព") ដែលគេរង់ចាំជាយូរមកហើយនោះ បានអនុម័តនៅឆ្នាំ២០១០ ដែលមានរយៈពេលប្រហែល១៥ឆ្នាំ បន្ទាប់ពីត្រូវបានស្នើឡើងពីដំបូងបង្ហាញពុំមានឥទ្ធិពលនោះទេ ព្រោះអំណាចក្នុងការនាំទៅរកការផ្តន្ទាទោសតាមបទប្បញ្ញត្តិរបស់ច្បាប់នេះនៅតែអាស្រ័យលើស្ថាប័នតុលាការដែលស្ថិតនៅក្រោមឥទ្ធិពលរបស់ស្ថាប័ននីតិប្រតិបត្តិ។ ច.ប្រ.ព មិនទាន់មានអានុភាពគ្រប់គ្រាន់នៅឡើយទេ ដែលធ្វើឲ្យបរាជ័យក្នុងការបង្កើតជាស្ថាប័នមួយមានឯករាជ្យភាព តម្លាភាព ដើម្បីត្រួតពិនិត្យនូវការអនុវត្តច្បាប់ ហើយក្នុងស្ថានភាពបែបនេះ ពុំមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីដោះស្រាយបញ្ហាអំពើពុករលួយឲ្យមានប្រសិទ្ធភាពនោះឡើយ។ សមាជិករបស់ស្ថាប័ននានាភាគច្រើនដែលបានបង្កើតឡើងក្រោមច.ប្រ.ព គឺត្រូវបានតែងតាំងដោយនាយករដ្ឋមន្ត្រី[5] ហើយស្ថាប័ននេះត្រូវតែរាយការណ៍ដោយផ្ទាល់ទៅនាយករដ្ឋមន្ត្រី។[6] យន្តការនានាដែលបានកំណត់ដោយ ច.ប្រ.ព ខ្វះតម្លាភាព ហើយជាថ្មីទៀត ឥទ្ធិពលរបស់ស្ថាប័ននីតិប្រតិបត្តិកំពុងតែធ្វើការគាបសង្កត់ទៅលើស្ថាប័នឯករាជ្យនានា។ ច.ប្រ.ព គ្មានទស្សនៈវិស័យក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយក្នុងជួរ រ.ស.ក ទេ ដ៏រាបណាស្ថាប័នទាំងឡាយណាដែលអនុវត្ត ច.ប្រ.ព នៅតែស្ថិតនៅក្រោមការគ្រប់គ្រងពីសំណាក់រដ្ឋាភិបាល។

**<u>ធនធាន និងការបណ្តុះបណ្តាលមិនគ្រប់គ្រាន់</u>**

---

[5]មាត្រា៦ និងមាត្រា១១នៃ ច.ប្រ.ព

[6]មាត្រា១០ និងមាត្រា១៣ នៃ ច.ប្រ.ព

វិស័យតុលាការ និងច្បាប់ត្រូវបានបំផ្លាញខ្ទេចខ្ទីអំឡុងពេលរបបខ្មែរក្រហម ហើយ រ.រ.ក បានធ្វើឲ្យមានភាពរីកចម្រើនគួរឲ្យកោតសរសើរក្នុងការការកសាងឡើងវិញនូវវិស័យទាំងនេះ និងការសម្របសម្រួលឲ្យមានវគ្គបណ្តុះបណ្តាលផ្នែកវិជ្ជាជីវៈ បើទោះជាមានកិច្ចការជាច្រើនទៀតដែលនឹងត្រូវធ្វើបន្តទៀតក៏ដោយ។ ភ្លាមៗបន្ទាប់ពីមានការប្រកាសឲ្យប្រើរដ្ឋធម្មនុញ្ញក្នុងឆ្នាំ១៩៩៣ ចៅក្រម និងមេធាវីភាគច្រើនទទួលបានការបណ្តុះបណ្តាលតិចតួច ឬក៏គ្មានសោះតែម្តង។[7] រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ("រាជបណ្ឌិតសភា") បានបើកដំណើរការក្នុងឆ្នាំ ២០០៣ និងដោយមានក្តីសង្ឃឹមថាស្ថាប័ននេះនឹងផ្តល់ឲ្យទាន់ពេលវេលានូវកម្រិតនៃការបណ្តុះបណ្តាល និងអប់រំមួយដ៏ចាំបាច់ ដើម្បីធ្វើឲ្យអ្នកជំនាន់ថ្មីទទួលបានការអប់រំមានគុណភាពល្អ ប្រកបដោយសមត្ថភាព និងសមត្ថភាពផ្នែកវិជ្ជាជីវៈ។ យ៉ាងណាក្តី បច្ចុប្បន្ននេះ កិត្យានុភាពរបស់រាជបណ្ឌិតសភាបានធ្លាក់ចុះដោយមានការចោទប្រកាន់ថាមានការទទួលសំណូក និងប្រព្រឹត្តអំពើពុករលួយ ដោយការតែងតាំងចៅក្រមជាញឹកញាប់ផ្តល់ទៅអ្នកដែលហ៊ានឲ្យថ្លៃខ្ពស់ ជាជាងបេក្ខជនដែលមានសមត្ថភាពខ្ពស់បំផុត។[8]

គម្រោងសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ជារឿយៗ ឃ្លាំមើលក្នុងសំណុំរឿងដែលចៅក្រមប្រកាសសាលក្រម ដែលមានហេតុផលផ្លូវច្បាប់ពុំគ្រប់គ្រាន់ ឬស្ទើរតែគ្មានតែម្តង ខណៈដែលគុណភាពនៃទឡ្ហីករណ៍ផ្នែកច្បាប់ក្នុងតុលាការមានភាពទន់ខ្សោយជាខ្លាំង។ ជាងនេះទៅទៀតភាពស្មុគស្មាញនៃច្បាប់ជាញឹកញាប់ត្រូវបានដើរវំលង ហើយភស្តុតាងគឺកម្រត្រូវបានត្រួតពិនិត្យឲ្យបានសព្វគ្រប់ណាស់ ការជំនុំជម្រះក្តីត្រូវបានធ្វើឡើងយ៉ាងតក់ក្រហល់ ដែលជារឿយៗសាលក្រមមានទំនាក់ទំនងតិចតួចលើភស្តុតាងដែលបានបង្ហាញ ហើយការផ្តន្ទាទោសជាទម្លាប់ផ្អែកលើការសារភាព បើទោះជាពុំមានភស្តុតាងបញ្ជាក់បន្ថែមយ៉ាងណាក្តី។ ភាពទន់ខ្សោយបែបនេះនៅក្នុងវិស័យច្បាប់ និងតុលាការគឺជាលទ្ធផលនៃអំពើពុករលួយ ហើយការបណ្តុះបណ្តាលនៅមានកម្រិតទាប គឺរឹងរឹតតែមានកង្វះខាតធនធានទាំងផ្នែកបុគ្គលិកលក្ខណៈ និងផ្នែកហិរញ្ញវត្ថុ។ អំឡុងពេលនៃកិច្ចប្រជុំពិភាក្សារវាងសមាជិកនៃស្ថាប័នតុលាការ ជាមួយនឹងអ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ចៅក្រមបានបញ្ជាក់ថា មេធាវីការពារជនជាប់ចោទ ពេលខ្លះត្រូវបានតែងតាំងនៅថ្ងៃជំនុំជម្រះក្តីតែម្តង ដោយសារតែពុំមានមេធាវីគ្រប់គ្រាន់ ដើម្បីបំពេញតាមតម្រូវការ និងនីតិវិធីជាមូលដ្ឋាន ដូចជាការដាក់បង្ហាញនូវការជូនដំណឹងជាសាធារណៈនៃសវនាការ។ ចំនួនមេធាវីនៅពុំទាន់គ្រប់គ្រាន់ ជាពិសេសមេធាវីការពារជនជាប់ចោទ ក្លាយជាឧបសគ្គក្នុងការទទួលបានយុត្តិធម៌ ហើយក៏មានផលប៉ះពាល់អវិជ្ជមានផងដែរលើគុណភាពនៃអ្នកតំណាង ប្រសិនជាមេធាវីមិនត្រូវបានផ្តល់ពេលវេលាគ្រប់គ្រាន់ដើម្បីត្រៀមការពារក្តីក្នុងសំណុំរឿងនោះទេ។

---

[7]លោកបណ្ឌិត ឡៅ ម៉ុងហៃ 'វិទ្យាស្ថានសម្រាប់នីតិរដ្ឋ និងសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា' (*គណៈកម្មការសិទ្ធិមនុស្សអាស៊ាន* ទថ្មី) អាចស្វែងរកបានតាមរយៈ៖www.humanrights.asia/resources/journals-magazines/article2/0501/institutions-for-the-rule-of-law-and-human-rights-in-cambodia

[8]គណៈកម្មការសិទ្ធិមនុស្សអាស៊ាន ' ដើម្បីក្លាយជាចៅក្រម គឺត្រូវត្រៀមខ្លួនសូកប៉ាន់'(ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៩) អាចស្វែងរកបានតាមរយៈ៖www.humanrights.asia/news/forwarded-news/AHRC-FAT-004-2009/?searchterm

ការខកខានពុំបានអនុវត្តតាមនីតិវិធីច្បាប់ជាមូលដ្ឋាន ក៏អាចត្រូវបានចាត់ទុកជាលទ្ធផលនៃកង្វះខាតវគ្គបណ្តុះបណ្តាលផ្នែកច្បាប់ដែលមានគុណភាពផងដែរ។ ចៅក្រមជាញឹកញាប់ពុំបានផ្តល់ប្រឹក្សាឲ្យបានសមរម្យដល់ជនជាប់ចោទអំពីសិទ្ធិកំណត់ដោយច្បាប់របស់ពួកគេ ហើយនៅពេលដែលជនជាប់ចោទរម្លឹកដល់សិទ្ធិរបស់ខ្លួន ចៅក្រមតែងតែពុំផ្តល់នូវការពន្យល់ឲ្យបានគ្រប់គ្រាន់ដល់ពួកគេ។ អំឡុងពេលនៃរបាយការណ៍លើកទីប្រាំនៃគម្រោងសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ចៅក្រមបានជូនដំណឹង និងពន្យល់អំពីសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការការពារស្របច្បាប់ និងសិទ្ធិក្នុងការរក្សានូវភាពស្ងៀមស្ងាត់ មានត្រឹមតែ២%ភាគរយប៉ុណ្ណោះក្នុងចំណោមករណីដែលបានសង្កេតការណ៍។[9] ក្នុងអំឡុងពេលនៃរបាយការណ៍ដូចគ្នានេះ ចៅក្រមទទួល ទូរសព្ទក្នុងពេលវនាការមាន៣២%។[10] ការប្រព្រឹត្តបែបនេះធ្វើឲ្យប៉ះពាល់ជាខ្លាំងដល់ភាពត្រឹមត្រូវនៃដំណើរការនីតិវិធី និងពុំបានធ្វើអ្វី ដើម្បីលើកម្ពស់នូវកេរ្តិ៍ឈ្មោះវិជ្ជាជីវៈក្នុងចំណោមចៅក្រម។

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ស្របពេលដែលការផ្លាស់ប្តូរសំខាន់ៗមានភាពចាំបាច់ជាមូលដ្ឋាន និងជាគោលដៅមួយពិបាកនឹងសម្រេចបាន យ៉ាងណាក៏ដោយ ម.ស.ម.ក ចាត់ទុកថាចំណុចនេះមានលក្ខណៈប្រាកដប្រជា និងអាចសម្រេចបាន។ ច្បាប់សំខាន់ៗជាច្រើនមានរួចទៅហើយ ទាំងស្ថិតនៅជាទម្រង់សេចក្តីព្រាង និងច្បាប់ដែលបានអនុម័តរួច ហើយច្បាប់ទាំងនេះចាំបាច់ត្រូវពង្រឹង និងកែច្នៃ ដើម្បីដោះស្រាយការព្រួយបារម្ភនានាដែលបានលើកឡើងនៅក្នុងកំណត់ត្រាសង្ខេបនេះ។ អនុសាសន៍នានាទាក់ទិនទៅនឹងការបណ្តុះបណ្តាល និងការអប់រំអាចត្រូវបានចាប់ផ្តើមធ្វើក្នុងរយៈពេលដ៏ខ្លី ព្រមទាំងអាចអនុវត្តទៅបាន និងមាននិរន្តរភាព លុះត្រាតែធនធានផ្នែកហិរញ្ញវត្ថុ និងធនធានមនុស្សគ្រប់គ្រាន់ត្រូវបានបង្កើតឲ្យមាន និងដរាបណា រ.រ.ក មានឆន្ទៈធ្វើការប្តេជ្ញាពិតប្រាកដ ដើម្បីធ្វើកំណែទម្រង់ប្រព័ន្ធតុលាការពោរពេញដោយអត្ថន័យ។

<u>**ពន្លឿនការអនុម័តលើសេចក្តីព្រាងច្បាប់នានា៖**</u> បទដ្ឋានច្បាប់សំខាន់ៗត្រូវតែធ្វើឲ្យកាន់តែល្អឡើង និងបញ្ចប់ហេតុដូច្នេះការអនុម័តលើច្បាប់ទាំងនោះ អាចត្រូវធ្វើបានលឿន។ ច្បាប់បែបនេះគឺមានសារៈសំខាន់ណាស់ក្នុងការសម្រេចឲ្យបាននូវទិសដៅនៃយុទ្ធសាស្ត្រ និងក្នុងការសម្រេចឲ្យបាននូវប្រព័ន្ធតុលាការ និងច្បាប់ប្រកបដោយឯករាជ្យ និងមិនលម្អៀង ដែលមានសមត្ថភាពការពារសិទ្ធិរបស់ប្រជាពលរដ្ឋគ្រប់រូប។ ដូច្នេះ ម.ស.ម.ក ផ្តល់នូវអនុសាសន៍ថាច្បាប់មួយចំនួនដូចខាងក្រោម គឺត្រូវតែប្រញាប់ប្រញាល់ និងអនុម័តក្នុងស្ថានភាពជាបន្ទាន់៖

- ច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់តុលាការ
- ច្បាប់ស្តីពីលក្ខន្តិកៈរបស់ចៅក្រម និងព្រះរាជអាជ្ញា
- ច្បាប់ស្តីពីយុត្តិធម៌អនីតិជន

---

[9] ទិន្នន័យពាក់ព័ន្ធទៅនឹងសាលាដំបូងរាជធានីភ្នំពេញតែប៉ុណ្ណោះ ចាប់ពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០១១ ដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១២
[10] ទិន្នន័យពាក់ព័ន្ធទៅនឹងសាលាដំបូងរាជធានីភ្នំពេញ

**ធ្វើវិសោធនកម្មបន្ថែមលើច្បាប់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម៖** មុនពេលការធ្វើវិសោធនកម្មលើសេចក្ដីព្រាងច្បាប់បច្ចុប្បន្ននេះត្រូវបានអនុម័ត ច្បាប់ទាំងនោះ ត្រូវតែធ្វើការកែសម្រួលដើម្បីធានាពីឯករាជ្យភាពរបស់ស្ថាប័នតុលាការពីស្ថាប័ននីតិប្រតិបត្តិ។ ដូច្នេះ ម.ស.ម.ក ផ្ដល់នូវអនុសាសន៍ថា៖

- ការធ្វើវិសោធនកម្មលើច្បាប់ស្ដីពី ឧ.អ.ច គួរតាក់តែងច្បាប់ដែលមិនដាក់បញ្ចូលនូវសមាជិកណាមួយរបស់ស្ថាប័ននីតិប្រតិបត្តិឲ្យមានតំណែងក្នុង ឧ.អ.ច នោះឡើយ

**ការធ្វើវិសោធនកម្មលើច្បាប់ប្រឆាំងអំពើពុករលួយ៖** វិសោធនកម្មគួរតែត្រូវបានធ្វើឡើងលើច្បាប់ប្រឆាំងអំពើពុករលួយ ដើម្បីធានាថា ស្ថាប័ននានា ដែលបានបង្កើតតាមច្បាប់នេះ មានឯករាជ្យ និងតម្លាភាពទាំងស្រុង។ ដោយហេតុនេះ ម.ស.ម.ក ផ្ដល់នូវអនុសាសន៍មួយចំនួនដូចខាងក្រោម៖

- ការធ្វើវិសោធនកម្មដោយត្រូវតែធានាថា ស្ថាប័ននានា ដែលបានបង្កើតតាមច្បាប់ប្រឆាំងអំពើពុករលួយត្រូវទទួលខុសត្រូវចំពោះអង្គចៅក្រម ហើយមិនមែនចំពោះនាយករដ្ឋមន្ត្រីនោះទេ
- ការធ្វើវិសោធនកម្មត្រូវតែធានាថា ការទទួលខុសត្រូវចំពោះនិយតកម្មនៃស្ថាប័នទាំងនេះ អាស្រ័យលើស្ថាប័នតុលាការឯករាជ្យមួយ ហើយមិនមែនអាស្រ័យលើស្ថាប័ននីតិប្រតិបត្តិនោះទេ

**បង្កើនការអប់រំ/ការយល់ដឹងពីសិទ្ធិ៖** ការអប់រំ និងការយល់ដឹងពីសិទ្ធិត្រូវតែបង្កើនឡើងមិនត្រឹមតែជូនដំណឹងដល់ប្រជាពលរដ្ឋឲ្យបានយល់ដឹងពីសិទ្ធិរបស់ពួកគេ និងវិធីដើម្បីទទួលបានសិទ្ធិទាំងនោះប៉ុណ្ណោះទេ តែថែមទាំងបង្កើនចលនាឲ្យមានការគាំទ្រជាសាធារណៈលើការធ្វើកំណែទម្រង់ប្រព័ន្ធតុលាការ។ ភាពរីកចម្រើននេះអាចសម្រេចបានតាមការចែករំលែកព័ត៌មានឲ្យដល់ជនជាប់ចោទនៅតាមតុលាការ និងដល់ពន្ធនាគារនានាដូចខាងក្រោមនេះ៖

- **ជនជាប់ចោទជារឿយៗ ពុំយល់ដឹងពីសិទ្ធិស្របច្បាប់របស់ខ្លួន ហើយព័ត៌មានគួរតែត្រូវចែកចាយទៅដល់បុគ្គលគ្រប់រូបដែលពាក់ព័ន្ធក្នុងសំណុំរឿងតុលាការ តាំងពីការចាប់ផ្ដើមនៃដំណើរការនីតិវិធី។ ខិតប័ណ្ណ និង/ឬក៏ប័ណ្ណផ្សព្វផ្សាយសាមញ្ញនានា គួរតែត្រូវបានចែកចាយទៅដល់ប៉ុស្ដិ៍នគរបាល និងពន្ធនាគារ ដែលជាកន្លែងជនជាប់ចោទត្រូវបានឃុំខ្លួនរង់ចាំការជំនុំជម្រះ ដែលមានកំណត់អំពីសិទ្ធិស្របច្បាប់របស់ពួកគេ និងអ្វីដែលគេទទួលបាន។**
- **ព័ត៌មានដូចគ្នានេះគួរតែអាចរកបាននៅតាមតុលាការ ហើយគ្រប់ស្ថាប័នតុលាការ/ពន្ធនាគារទាំងអស់គួរតែរក្សាបញ្ជីរាយនាមមេធាវីជំនួយផ្នែកច្បាប់ ដោយមានជាមួយនឹងព័ត៌មានសម្រាប់ទំនាក់ទំនងលម្អិតរបស់មេធាវីនានាអាចរកបានសម្រាប់ជនជាប់ចោទ។**

**ធ្វើឲ្យការបណ្ដុះបណ្ដាល និងធនធាននានាបានប្រសើរឡើងនៅក្នុងវិស័យតុលាការ និងច្បាប់ ព្រមទាំងធ្វើបទបង្ហាញពីក្រមសីលធម៌វិជ្ជាជីវៈចៅក្រម៖** ការបណ្ដុះបណ្ដាលត្រូវតែធ្វើឲ្យបានប្រសើរឡើងតាំងពីដំណាក់កាលដំ

បួង ដោយផ្តោតលើទឡ្ហីករណ៍ផ្នែកច្បាប់ វិធាននៃភស្តុតាង និងគោលការណ៍នៃបទដ្ឋានទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ដូចនេះ ម.ស.ម.ក ធ្វើការផ្តល់នូវអនុសាសន៍មួយចំនួនដូចខាងក្រោម៖

- គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា គួរតែបំពេញនូវតួនាទីសកម្មបន្ថែមទៀតចំពោះការអប់រំដល់សិក្ខាកាមជាមេធាវី ហើយព្រមទាំងបង្កើតឲ្យមានគម្រោងអភិវឌ្ឍផ្នែកវិជ្ជាជីវៈប្រកបដោយប្រសិទ្ធភាពដល់មេធាវីក្រុបកវិជ្ជាជីវៈ
- ធនធានខាងហិរញ្ញវត្ថុបន្ថែម គួរតែត្រូវបញ្ចូនទៅក្នុងវិស័យច្បាប់ និងតុលាការ ដើម្បីធានាថា តុលាការមានសម្ភារៈគ្រប់គ្រាន់ និងមានមេធាវីផ្តល់ជំនួយផ្នែកច្បាប់គ្រប់គ្រាន់។
- ក្រមសីលធម៌សម្រាប់ចៅក្រមដ៏រឹងមាំ គួរតែត្រូវបានព្រាងឡើង និងត្រូវអនុវត្តដោយ ឧ.អ.ច ដើម្បីធានាឲ្យមានបទដ្ឋានវិជ្ជាជីវៈគ្រប់គ្រាន់នៅក្នុងស្ថាប័នតុលាការ។

*ស្ថាប័នតុលាការ និង រ.រ.ក ត្រូវធ្វើការប្តេជ្ញាជាបន្ទាន់ក្នុងការបញ្ឈប់នូវការយាយីតាមផ្លូវតុលាការលើអ្នកការពារ និងសកម្មជនសិទ្ធិមនុស្សនានា៖* អនុសាសន៍ដែលលើកឡើងតាមប្រភេទខាងលើនេអាចអនុវត្តបានយ៉ាងជោគជ័យ ប្រសិនបើស្ថាប័នតុលាការ និងអង្គនីតិប្រតិបត្តិធ្វើការប្តេជ្ញាចិត្តពិតប្រាកដ ដើម្បីបញ្ឈប់ជាបន្ទាន់ក្នុងការប្រើប្រាស់តុលាការ ដើម្បីបំបិទសំឡេងអ្នកមាននិន្នាការនយោបាយប្រឆាំង និងអ្នករិះគន់លើ រ.រ.ក និងសមាជិករបស់ខ្លួន៖

- រ.រ.ក និងតុលាការត្រូវតែបញ្ឈប់នូវការយាយីតាមផ្លូវតុលាការលើក្រុមអ្នកការពារសិទ្ធិមនុស្ស សកម្មជននយោបាយ និងអ្នកនយោបាយមកពីគណៈបក្សប្រឆាំង។
- រ.រ.ក ត្រូវតែយល់ព្រមដោះលែងជាបន្ទាន់ និងគ្មានលក្ខខណ្ឌចំពោះបុគ្គលទាំងឡាយណា ដែលកំពុងតែឃុំខ្លួនចំពោះការផ្តន្ទាទោសដោយមានចរិតលក្ខណៈនយោបាយ ដែលពុំមានមូលដ្ឋានផ្នែកច្បាប់ និងពុំស្របតាមលទ្ធិប្រជាធិបតេយ្យសេរី។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក អ៊ូ វីរៈ តាមរយៈទូរសព្ទ៖ (+៨៥៥ (០) ១២ ៤០៤ ០៥១) ឬអ៊ីម៉ែល៖ ouvirak@cchrcambodia.orgឬ លោក រ៉ូប៊ឺត ហ្វីនច៍ ទីប្រឹក្សាជាន់ខ្ពស់ តាមរយៈទូរសព្ទ៖ (+៨៥៥ (០) ៧៨ ៨០៩ ៩៦០) ឬអ៊ីម៉ែល៖ robert.finch@cchrcambodia.org។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights
BY NC SA